ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# ខ្លឹមសារសង្ខេបប្រតិបត្តិ

នៅទូទាំងពិភពលោក សមាជិកសភាកំពុងប្រឈមនឹងហានិភ័យកាន់តែខ្លាំងឡើង។
បើយោងតាមសហភាពអន្តរសភា (IPU) នៅក្នុងឆ្នាំ២០១៩
មានសមាជិកសភាចំនួន៥៣៣នាក់ នៅក្នុងប្រទេសចំនួន៤០
បានប្រឈមនឹងការរំលោភសិទ្ធិមនុស្ស
ដោយតំបន់អាស៊ីជាតំបន់ដែលមានគ្រោះថ្នាក់បំផុតទី២។ នៅតំបន់អាស៊ីអាគ្នេយ៍
លទ្ធិប្រជាធិបតេយ្យក៏កំពុងស្ថិតនៅក្រោមការគម្រាមកំហែងនៃជនផ្តាច់ការ
ដែលកំពុងកាត់បន្ថយការការពារសិទ្ធិ និងកំពុងបំផ្លាញស្ថាប័នប្រជាធិបតេយ្យ។

របាយការណ៍នេះឆ្លុះបញ្ចាំងឲ្យឃើញពីរបៀបដែលរដ្ឋាភិបាលមួយចំនួននៅក្នុងតំបន់បានកំពុ
ងកំណត់មុខសញ្ញាលើសមាជិកសភានៃគណបក្សប្រឆាំង
ដែលជាផ្នែកមួយនៃការប៉ុនប៉ងកាន់តែទូលំទូលាយរបស់ខ្លួនក្នុងការបង្ក្រាបអ្នកប្រឆាំង
និងដើម្បីទទួលបានអំណាចដែលគ្មានការត្រួតពិនិត្យ។

ការស្រាវជ្រាវមួយរបស់ក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR)
ទៅលើតំបន់ទាំងមូល បង្ហាញថា នៅក្នុងប្រទេសថៃ និងប្រទេសហ្វីលីពីន
អាជ្ញាធរកំពុងតែប្រើយុទ្ធសាស្ត្រមួយចំនួន ដើម្បីបំភិតបំភ័យ
និងយាយីសមាជិកសភានៃគណបក្សប្រឆាំង
ជាពិសេសកាន់តែខ្លាំងឡើងនៅក្នុងប្រទេសម៉ាឡេស៊ី។ យុទ្ធសាស្ត្រទាំងនេះរួមមាន
ការបង្កើតសំណុំរឿងដែលមានលក្ខណៈនយោបាយ
ការដកសមាជិកសភាពីអាសនៈសភារបស់ខ្លួន ការគម្រាមកំហែង
ឬការតាមដានឃ្លាំមើលសមាជិកសភានៃគណបក្សប្រឆាំង
និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិតតាមអ៊ីនធឺណេត។
សមាជិកសភាជាស្ត្រីក៏បានបញ្ជាក់ប្រាប់ APHR
អំពីការនិយាយមួលបង្កាច់កេរ្តិ៍ដោយមានការប្រកាន់ភេទដែលពួកគេបានប្រឈម
និងកត្តាដែលបង្កឲ្យមានបញ្ហាបន្ថែមទៀតដល់ពួកគេ។
ការធ្វើទុក្ខបុកម្នេញទាំងនេះមិនត្រឹមតែរំលោភលើសិទ្ធិជាមូលដ្ឋានរបស់សមាជិកសភាដែល
ត្រូវបានកំណត់ជាមុខសញ្ញានោះទេ
ប៉ុន្តែថែមទាំងមានគោលបំណងរឹតត្បិតលំហប្រជាពលរដ្ឋ
និងបំផ្លាញភាពជាតំណាងប្រជាធិបតេយ្យទៀតផង។ ក្នុងពេលតែមួយដូចគ្នា
អាជ្ញាធរនៃប្រទេសទាំងនោះបានអនុវត្តការបង្ក្រាបកាន់តែខ្លាំងទៅលើអ្នកការពារសិទ្ធិមនុ
ស្ស សារព័ត៌មាន និងក្រុមប្រឆាំងដទៃផ្សេងទៀត។

យុទ្ធសាស្ត្រចម្បង គឺការបើកការស៊ើបអង្កេត
ឬការចោទប្រកាន់ពីបទដែលត្រូវបានប្រឌិតឡើង។ APHR រកឃើញថា
ចាប់តាំងពីដើមឆ្នាំ២០១៨មក
មានសមាជិកសភានៃគណបក្សប្រឆាំងយ៉ាងហោចណាស់២៧នាក់ នៃប្រទេសថៃ ម៉ាឡេស៊ី
និងហ្វីលីពីន ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ប៉ូលិស
ព្រមទាំងរងការដាក់ពាក្យបណ្តឹង ឬត្រូវបានចោទប្រកាន់ ឬកាត់ទោស
ដោយសារគ្រាន់តែបានប្រើប្រាស់សិទ្ធិមនុស្សរបស់ខ្លួនប៉ុណ្ណោះ។
ការឃាយីតាមប្រព័ន្ធតុលាការជាច្រើនមានលក្ខណៈមិនស្របច្បាប់ឡើយ
ដោយករណីតិចតួចប៉ុណ្ណោះនាំឲ្យមានការផ្តន្ទាទោស
ដែលនេះបង្ហាញឲ្យឃើញពីគំរូនៃការបំភិតបំភ័យ។

សមាជិកសភាដែលត្រូវបានកំណត់ជាមុខសញ្ញា
គឺជាសមាជិកគណបក្សប្រឆាំងដែលរិះគន់រដ្ឋាភិបាល
និងគោលនយោបាយរបស់រដ្ឋាភិបាលដោយឥតសំចៃមាត់
ឬបានប្រជែងគ្រប់គ្រងអំណាចនយោបាយ។
នៅក្នុងករណីនៃសមាជិកសភាមកពីគណបក្សអនាគតថ្មី (Future Forward Party)
នៅក្នុងប្រទេសថៃ ដែលត្រូវបានរំលាយទៅហើយនោះ ករណីអតីតសមាជិកព្រឹទ្ធសភា
Trillanes និងករណីក្រុម Makabayan នៅក្នុងប្រទេសហ្វីលីពីន
ព្រមទាំងចំនួនដ៏ច្រើននៃពាក្យបណ្តឹង ការគម្រាមកំហង
និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិតប្រឆាំងសមាជិកសភាទាំងនោះ
បង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីការប៉ុនប៉ងដែលមានលក្ខណៈជាប្រព័ន្ធ
និងចេតនាក្នុងការបំបិទសំឡេងសមាជិកសភាទាំងនោះ។ ទន្ទឹមនឹងនេះ
ករណីនៅក្នុងប្រទេសម៉ាឡេស៊ី សមាជិកសភាដែលធ្លាប់ជារដ្ឋមន្ត្រីនៅក្នុងអតីតរដ្ឋាភិបាល
Pakatan Harapan ដែលត្រូវបានទម្លាក់ពីអំណាចដោយកលល្បិចស្មោគគ្រោក
កាលពីខែមីនា ឆ្នាំ២០២០កន្លងទៅ ទំនងជានឹងត្រូវកំណត់ជាមុខសញ្ញា។

នៅក្នុងករណីភាគច្រើន ពាក្យបណ្តឹងត្រូវបានផ្តួចផ្តើមធ្វើឡើងដោយប៉ូលិស មន្ត្រីយោធា
សមាជិកគ្រួសារនៃមេដឹកនាំនយោបាយ និងបុគ្គល ឬអង្គភាពដទៃផ្សេងទៀត
ដែលមានទំនាក់ទំនងជិតស្និទ្ធនឹងមន្ត្រីរដ្ឋាភិបាល។ លើសពីនេះទៀត
ពាក្យបណ្តឹងជាញឹកញាប់ផ្អែកទៅលើច្បាប់ដែលមានលក្ខណៈគាបសង្កត់
ដែលត្រូវបានប្រើជាញឹកញាប់ដើម្បីរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ
និងត្រូវបានមេធាវីសិទ្ធិមនុស្សអះអាងថា មិនស្របតាមច្បាប់អន្តរជាតិ។

ការប្រើប្រាស់ច្បាប់ និងប្រព័ន្ធច្បាប់ជាអាវុធ
ដើម្បីដកហូតសិទ្ធិរបស់ក្រុមប្រឆាំងពីនយោបាយទាំងស្រុង
តាមរយៈការរំលាយគណបក្សនយោបាយ
ដែលនាំឲ្យមានការដកហូតតំណែងសមាជិកសភាពីសភាតាមទំនើងចិត្ត
ដូចករណីដែលបានកើតឡើងចំពោះសមាជិកសភាចំនួន១២នាក់
មកពីគណបក្សអនាគតថ្មីនៃប្រទេសថៃ កាលពីខែកុម្ភៈ ឆ្នាំ២០២០
និងករណីសមាជិកគណបក្សសង្គ្រោះជាតិ នៃប្រទេសកម្ពុជា កាលពីឆ្នាំ២០១៧។

សមាជិកសភាដែលជាជនរងគ្រោះនៃការឃាយីតាមប្រព័ន្ធតុលាការជាញឹកញាប់ក៏ប្រឈមនឹ
ងការបំភិតបំភ័យតាមប្រព័ន្ធអ៊ីនធឺណេត និងសង្គមខាងក្រៅ រួមមានការគម្រាមកំហែង
ដូចជា ការអនុវត្តជាទម្លាប់នូវការលាភពណ៌ថាជា “ក្រុមក្រហមនិយម (red-tagging)”
នៅក្នុងប្រទេសហ្វីលីពីន ដែលសមាជិកសភាទាំងនោះត្រូវបានចោទប្រកាន់ថាជា
ជនកុម្មុយនីស្ត ឬអ្នកគាំទ្រកុម្មុយនីស្ត
ហើយត្រូវបានពិពណ៌នាថាជាការគម្រាមកំហែងដល់សន្តិសុខជាតិ។
សមាជិកសភានៃគណបក្សប្រឆាំងក៏ជាមុខសញ្ញានៃការតាមដានឃ្លាំមើល
និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិតដែលគាំទ្រដោយរដ្ឋាភិបាលផងដែរ
ខណៈដែលសមាជិកសភាជាស្ត្រីត្រូវប្រឈមនឹងការវាយប្រហារដោយភាពស្អប់ខ្ពើម
ដែលមានគោលបំណងបំភិតបំភ័យ និងបង្ខូចកេរ្តិ៍ឈ្មោះរបស់ពួកគេ។

ការឃាយី ការគម្រាមកំហែង និងការបំភិតបំភ័យសមាជិកសភា
បង្កផលវិបាកដល់បុគ្គលជាសមាជិកសភាផង ក៏ដូចជាដល់សង្គមជាតិទាំងមូលផង។
សមាជិកសភាបានលើកឡើងអំពីផលប៉ះពាល់ដ៏គួរឲ្យខ្លាច
ដែលធ្វើឲ្យពួកគេត្រូវតែគិតពិចារណាដោយប្រុងប្រយ័ត្នអំពីការលើកឡើងអំពីប្រធានបទជា
ក់លាក់មួយចំនួន ដូចជា បញ្ហាពាក់ព័ន្ធនឹងតួនាទីរបស់រាជាធិបតេយ្យ
និងយោធានៅក្នុងប្រទេសថៃ។ សមាជិកសភាទាំងនោះក៏បញ្ជាក់ដែរថា ការឃាយី
ជាពិសេសការដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ គឺជាយុទ្ធសាស្ត្រធ្វើឲ្យពួកគេខាតបង់ធនធាន
និងធ្វើឲ្យពួកគេមានស្មារតីមិនមូលក្នុងការបំពេញអាណត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព
ក្នុងនាមជាតំណាងរាស្ត្រ។

សមាជិកសភាក៏លើកឡើងផងដែរអំពីការណ៍ដែលត្រូវបង្កើនការការពារសុវត្ថិភាពផ្ទាល់ខ្លួន បន្ថែមដោយត្រូវបំពាក់កាមេរ៉ាសុវត្ថិភាព CCTV ព្រមទាំងត្រូវផ្លាស់ប្តូរផ្លូវធ្វើដំណើរជាទៀងទាត់ ឬជៀសវាងការធ្វើដំណើរម្នាក់ឯង។

ក្នុងនាមជាមេដឹកនាំនៅក្នុងសហគមន៍របស់ខ្លួន ការណ៍ដែលត្រូវបានលាភពណ៌ថាជា "ក្រុមក្រហមនិយម (red-tagging)" ឬក្លាយជាជនរងគ្រោះនៃយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិត ឬក៏ត្រូវប្រឈមនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋអ្វីមួយ សុទ្ធតែបង្កផលប៉ះពាល់មិនល្អដល់កិត្តិយស និងរូបភាពជាសាធារណៈរបស់សមាជិកសភា។

ការធ្វើទុក្ខបុកម្នេញបែបនេះក៏បង្កផលប៉ះពាល់មិនល្អកាន់តែទូលំទូលាយចំពោះភាពជាតំណាងប្រជាធិបតេយ្យ និងសង្គមជាតិទាំងមូលផងដែរ។ ការញុំាងឲ្យមានបរិយាកាសភ័យខ្លាចក្នុងចំណោមសមាជិកសភា បង្កជាការគម្រាមកំហែងដល់មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យដែលរឹងមាំ។ នៅពេលដែលសមាជិកសភាត្រូវបានវាយប្រហារ វានឹងធ្វើឲ្យភាពជាតំណាងសភាចុះខ្សោយ ហើយជាមួយគ្នានេះដែរក៏ធ្វើឲ្យចុះខ្សោយនូវសមត្ថភាពក្នុងការអនុវត្តការត្រួតពិនិត្យ និងតុល្យភាពលើអំណាចនីតិប្រតិបត្តិ និងសមត្ថភាពក្នុងការការពារសេរីភាពជាមូលដ្ឋាន។

ការកំណត់មុខសញ្ញាលើបុគ្គលសាធារណៈ ដូចជា សមាជិកសភាជាដើម ក៏បង្កឲ្យមានបរិយាកាសភ័យខ្លាចនៅក្នុងសង្គម និងបញ្ឈប់មិនឲ្យមានការពិភាក្សាវែកញែក និងលំហប្រជាពលរដ្ឋ។ ឧទាហរណ៍ សមាជិកសភាលេចធ្លោនៃគណបក្សប្រឆាំង ដែលប្រឈមនឹងការចោទប្រកាន់ដែលត្រូវបានប្រឌិតឡើង និងការវាយប្រហារធ្ងន់ធ្ងររាប់មិនអស់ បានផ្តាំផ្ញើនូវសារមួយយ៉ាងច្បាស់ថា មនុស្សគ្រប់រូបនៅក្នុងសង្គមសុទ្ធតែអាចប្រឈមនឹងបញ្ហាស្រដៀងគ្នានេះ។

គំរូនៃការបំភិតបំភ័យដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ មានលក្ខណៈស្រដៀងគ្នានឹងគំរូដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលនៃប្រភេទដូចគ្នា ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន ព្រមទាំងអ្នកគាំទ្រលទ្ធិប្រជាធិបតេយ្យ និងសកម្មជននយោបាយ ហើយជាផ្នែកមួយនៃការប៉ុនប៉ងកាន់តែទូលំទូលាយក្នុងការបំបិទសំឡេងរិះគន់ទាំងអស់ និងបំបាត់នូវរាល់ទម្រង់នៃគណនេយ្យភាព។

របាយការណ៍នេះត្រូវបានបញ្ចប់ដោយការលើកឡើងនូវអនុសាសន៍សំខាន់ៗសម្រាប់ភាគីពាក់ព័ន្ធមួយចំនួន រួមមាន ការអំពាវនាវដល់រដ្ឋាភិបាលថៃ ម៉ាឡេស៊ី និងហ្វីលីពីន ឲ្យទម្លាក់ចោលជាបន្ទាន់នូវការចោទប្រកាន់ និងការស៊ើបអង្កេតដែលមានលក្ខណៈនយោបាយ និងបញ្ឈប់ការការគម្រាមកំហែង និងការយាយីសមាជិកសភានៃគណបក្សប្រឆាំងតាមគ្រប់ទម្រង់។ ប្រធានសភាត្រូវធានាផងដែរថា សិទ្ធិបញ្ចេញមតិរបស់សមាជិកសភាទាំងអស់ត្រូវបានការពារ និងធានាថា សមាជិកសភាអនុវត្តអាណត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដោយគ្មានការភ័យខ្លាចអំពីការធ្វើទុក្ខបុកម្នេញ។ ជាទីបញ្ចប់ សមាជិកសភាដូចគ្នា និងគណៈកម្មាធិការអចិន្ត្រៃយ៍សភាដែលពាក់ព័ន្ធ ត្រូវប្រើប្រាស់អាណត្តិរបស់ខ្លួនដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៃសហសេវិករបស់ខ្លួន រួមមានការអំពាវនាវឲ្យមានការទម្លាក់ចោលនូវការចោទប្រកាន់ ព្រមទាំងផ្តួចផ្តើមឲ្យមានការស៊ើបអង្កេត និងចោទជាសំណួរទៅរដ្ឋាភិបាល។

វិធីសាស្ត្រ
ការស្រាវជ្រាវនេះគឺផ្អែកទៅលើរបាយការណ៍ស្ទង់មតិចំនួន២ ដែល APHR បានធ្វើជាមួយសមាជិករបស់ខ្លួន កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ និងខែមីនា ឆ្នាំ២០២០

ដែលក្នុងនោះមានសមាជិកចំនួន២២នាក់បានចូលរួមចែករំលែកនូវព័ត៌មានលម្អិតអំពីបញ្ហា និងការរំលោភសិទ្ធិ ដែលសមាជិកទាំងនោះបានប្រឈមក្នុងពេលកាន់តំណែងជាសមាជិកសភា។ នៅចន្លោះពីខែមេសា ដល់ខែសីហា ឆ្នាំ២០២០ APHR ក៏បានសម្ភាសន៍សមាជិកសភាចំនួន៦០នាក់ដាច់ដោយឡែកពីគ្នាតាមវិធីសម្ភាសន៍ពាក់កណ្ដាលទម្រង់ (semi-structured interviews) ដោយក្នុងនោះ៣៥នាក់គឺជាអតីតសមាជិកសភា និងជាសមាជិកសភាក្នុងតំណែងនៃប្រទេសថៃ ទីម័រខាងកើត ម៉ាឡេស៊ី ហ្វីលីពីន មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី កម្ពុជា និងសិង្ហបុរី។ ក្នុងចំណោមនោះ គឺមាន១៨នាក់ជាបុរស និង ១៧នាក់ជាស្ត្រី។ APHR ក៏បានសម្ភាសន៍ជាមួយអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មានបុគ្គលិកអង្គការសហប្រជាជាតិ សាស្ត្រាចារ្យ និងអ្នកជំនាញផ្សេងទៀតផងដែរ។ APHR ក៏បានប្រមូល និងផ្ទៀងផ្ទាត់ឯកសារពាំនឹងពីអ្នកដែលផ្ដល់កិច្ចសម្ភាសន៍ រួមមានឯកសារតុលាការ រូបថតស្គ្រីននៃអត្ថបទបង្ហោះលើបណ្ដាញសង្គមនិងសេចក្ដីថ្លែងការណ៍នានា។ ឈ្មោះរបស់អ្នកដែលត្រូវបានសម្ភាសន៍ និងដកស្រង់ពាក្យសម្ដីត្រូវបានសរសេរកត់ត្រា តែក្នុងករណីមានការអនុញ្ញាតយល់ព្រមប៉ុណ្ណោះ។

របកគំហើញ និងការវិភាគ
ក៏ពឹងផ្អែកផងដែរលើការត្រួតពិនិត្យឯកសារយ៉ាងទូលំទូលាយលើឯកសារអក្សរសិល្ប៍ដែលមានស្រាប់ ពាក់ព័ន្ធនឹងបញ្ហាដែលត្រូវដោះស្រាយ រួមមានរបាយការណ៍របស់អង្គការសង្គមស៊ីវិល សហភាពអន្តរសភា (IPU) និងអង្គការសហប្រជាជាតិ ព្រមទាំងប្រភពព័ត៌មានដែលគួរឲ្យជឿជាក់។

APHR ក៏បានផ្ញើលិខិតស្នើសុំព័ត៌មានទៅគណបក្សនយោបាយចំនួន៩គណបក្ស ទាំងគណបក្សប្រឆាំង និងគណបក្សនៃរដ្ឋាភិបាលចម្រុះ នៅក្នុងប្រទេសចំនួន៧ ផងដែរ (ទីម័រខាងកើត សិង្ហបុរី ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា និងថៃ) ដើម្បីសួរអំពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលសមាជិកសភានៃប្រទេសទាំងនោះបានប្រឈម។ លិខិតទាំងនេះក៏ត្រូវបានផ្ញើទៅកាន់រដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ហ្វីលីពីន និងថៃ ដែលត្រូវបានថតចម្លងជូនប្រធានសភានៃប្រទេសទាំងនោះ ដើម្បីផ្ដល់ឱកាសដល់ពួកគេក្នុងការឆ្លើយតបទៅនឹងការរកឃើញនៅក្នុងរបាយការណ៍នេះ។ APHR មិនទទួលបានការឆ្លើយតបអ្វីឡើយចំពោះលិខិតទាំងនេះ។

របាយការណ៍នេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ APHR ក្នុងការចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្សដែលប្រឈមដោយសមាជិកសភានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីធានាថា សមាជិកសភាអាចអនុវត្តអាណត្តិរបស់ខ្លួនដោយគ្មានការភ័យខ្លាចពីការធ្វើទុក្ខបុកម្នេញ។ របាយការណ៍នេះផ្អែកទៅលើរបាយការណ៍របស់ APHR មុនៗ ដែលបានចងក្រងឯកសារអំពីការវាយប្រហារនានាប្រឆាំងនឹងសមាជិកសភានៅក្នុងប្រទេសកម្ពុជា និងហ្វីលីពីន៖ របាយការណ៍ស្ដីពីការសម្លាប់លទ្ធិប្រជាធិបតេយ្យ៖ ការវាយប្រហារទៅលើសមាជិកសភា និងការគម្រាមកំហែងដល់ស្ថាប័ននានារបស់ប្រទេសកម្ពុជា (មីនា ២០១៧) និងរបាយការណ៍ស្ដីពី ការវាយប្រហារក្នុងអាណត្តិប្រធានាធិបតី៖ ការវាយប្រហារទៅលើសមាជិកសភានៃគណបក្សប្រឆាំង នៅក្នុងប្រទេសហ្វីលីពីន (មិថុនា ២០១៩)។

APHR សូមថ្លែងអំណរគុណដោយស្មោះចំពោះសមាជិកសភាទាំងអស់ដែលបានចូលរួមចំណែកចំណាយពេលវេលា ចែករំលែកចំណេះដឹង និងផ្ដល់មតិយោបល់ណែនាំដល់របាយការណ៍នេះ និងសង្ឃឹមថា ព័ត៌មាន និងអនុសាសន៍មានក្នុងរបាយការណ៍នេះ នឹងមានប្រយោជន៍សម្រាប់គ្រប់ភាគីដែលចាប់អារម្មណ៍។